**អាស័យដ្ឋានទំនាក់ទំនង**

**គណៈអធិបតី / ប្រធាន**

**គណៈកម្មការវិទ្យាសាស្ត្រ**

បណ្ឌិត ស៊ិនជិ ស៊ឹការ៉ាគី មកពីសាកលវិទ្យាល័យកាណាហ្សាវ៉ា បណ្ឌិត ហាង ពៅ មកពីអាជ្ញាធរអប្សរា សាស្ត្រាចារ្យមាសាមុ ហ្វីរឹឈិ មកពីសាកលវិទ្យាល័យកាណាហ្សាវ៉ា សាស្ត្រាចារ្យ យូស៊ិហ៊ីកុ ហ៊ីរ៉ាប៊ីគិ មកពីសាលកវិទ្យាល័យតូហូគីហ្គាគីអ៊ីន និងសាស្ត្រាចារ្យយ៉ាសួគិ អូគីមុរ៉ា មកពីសាកលវិទ្យាល័យអូសាកាទំនាក់ទំនងអេឡិចត្រូនិច។

**លេខាធិការរបស់សន្និសិទ្ធ**


បណ្ឌិត ស៊ិនជិ ស៊ឹការ៉ាគី មកពីវិទ្យាស្ថានបច្ចេកវិទ្យាធម្មជាតិ និងបរិស្ថាននៃសាកលវិទ្យាល័យកាណាហ្សាវ៉ាប្រទេសជប៉ុន

ទូរស័ព្ទ : +៨១-៧៦-២៦៤-៥៨១៤

អ៊ីមែល : tukawaki@t.kanazawa-u.ac.jp

និង

បណ្ឌិត ហៃជិអូ អូយ៉ាគិ មកពីមហាវិទ្យាល័យមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រនៃសាលកវិទ្យា ល័យជប៉ុន ក្នុងទីក្រុងតូក្យូប្រទេសជប៉ុន

ទូរស័ព្ទ : +៨១-៣-៣៣២៩-១១៥១

អ៊ីមែល : oyagi@chs.nihon-u.ac.jp


**ទីកន្លែង និង កាលបរិច្ឆេទ**

**សន្និសិទ្ធអន្តរជាតិ**

ថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០០៩

នៅមហាសាលរបស់អង្គការ UNESCO/ JASA Central Hall ក្នុងការិយាល័យរបស់ JASA ខេត្តសៀមរាប ប្រទេសកម្ពុជា

**សិក្ខាសាលាស្រាវជ្រាវ**

ថ្ងៃទី ១៨ ខែមិនា ឆ្នាំ ២០០៩

នៅបន្ទប់សិក្ខាសាលានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា

**ភាសាប្រើប្រាស់ក្នុងសន្និសិទ្ធ**

ភាសាអង់គ្លេស គឺជាភាសាផ្លូវការដែលនឹងប្រើនៅក្នុងសន្និសិទ្ធ និង សិក្ខាសាលា។

**ការឈប់ទទួលអត្ថបទស្រាវជ្រាវ**

អត្ថបទសង្ខេបផុតកំណត់ត្រឹមថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩។ អត្ថបទស្រាវជ្រាវដែលបានអញ្ជើញ និងបានផ្តល់ជូន នឹងមានបោះពុម្ពផ្សាយនៅថ្ងៃសន្និសិទ្ធ។

**ប្រធានបទដែលនឹងបង្ហាញ**

-បរិស្ថានបរិយាកាស

-បរិស្ថានទឹក

-វិស្វកម្មទន្លេ និងដី

-ជលធារវិទ្យា និង ជីវៈចំរុះ

-បរិស្ថានព្រៃ

**តម្លៃនៃការចុះឈ្មោះ**

ឥតគិតថ្លៃ

---

**អំពីក្រុម ERDAC (Environment Research Development in Angkor, Cambodia : ការស្រាវជ្រាវអំពីការវិវឌ្ឍន៏បរិស្ថានក្នុងតំបន់អង្គរ ប្រទេសកម្ពុជា)**

ក្រុម ERDAC បានបង្កើតឡើងដំបូងក្នុងលក្ខណៈជាក្រុមអ្នកស្រាវជ្រាវជប៉ុនមួយនៅ ខែមិនា ឆ្នាំ២០០៦ និងបានរៀបចំបង្កើតឡើងវិញនៅ ខែមិថុនា ឆ្នាំ២០០៦ ក្នុងលក្ខណៈជាបេសកកម្មសហប្រតិបត្តិការអន្តរជាតិជាមួយអាជ្ញាធរអប្សរា។ ក្រុមនេះមានបំណងធ្វើការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃការបំពុល និង ការបំផ្លាញបរិស្ថានក្នុង និងជុំវិញអង្គរ និងស្នើរជាផែនការកែប្រែដើម្បីឱ្យមានលក្ខណៈប្រសើរឡើង។

**ប្រទេសកម្ពុជា :** អាជ្ញាធរសម្រាប់ការការពារ និងគ្រប់គ្រងអង្គរនិងតំបន់សៀមរាប ដោយអាជ្ញាធរអប្សរា។

**ប្រទេសជប៉ុន :** សាកលវិទ្យាល័យកាណាហ្សាវ៉ា សាកលវិទ្យាល័យជប៉ុន សាកលវិទ្យាល័យតូក្យូ សាកលវិទ្យាល័យតូហូគីហ្គាគីអ៊ីន វិទ្យាស្ថានស្រាវជ្រាវប៊ីវ៉ាកូ សាកលវិទ្យាល័យតូក្យូនៃទំនាក់ទំនង សាកលវិទ្យាល័យអូសាកាអេឡិចត្រូនិចទំនាក់ទំនង និងសាកលវិទ្យាល័យក្យូតូ។

# សន្និសិទ្ធអន្តរជាតិ និង សិក្ខាសាលា ស្តីអំពីស្ថានភាពបច្ចុប្បន្ននៃបរិស្ថានក្នុងឧទ្យានអង្គរ និងតំបន់ជុំវិញអង្គរ ក្នុងប្រទេសកម្ពុជា

សន្និសិទ្ធ : ថ្ងៃទី ១៧ មិនា ឆ្នាំ ២០០៩ នៅខេត្តសៀមរាប

សិក្ខាសាលា : ថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០៩ នៅភ្នំពេញ

**ការបង្ហាញលើកទីដំបូង**

**និងមានប្រកាសទទួលបង្ហាញអត្ថបទស្រាវជ្រាវ**



**ឧបត្ថមដោយ**

-ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា

-អង្គការ UNESCO / ការិយាល័យនៅភ្នំពេញ

-គណៈកម្មការសម្របសម្រួលនៃកម្មវិធីភូគព្ភសាស្ត្រក្នុងតំបន់អាស៊ីបូពា៌ និងអាស៊ីអាគ្នេយ៏ (CCOP)

-វិទ្យាស្ថានបច្ចេកវិទ្យានៃកម្ពុជា (ITC)

## សន្និសិទ្ធអន្តរជាតិ និង សិក្ខាសាលា
## ស្តីអំពីស្ថានភាពបច្ចុប្បន្ននៃបរិស្ថានក្នុងឧទ្យានអង្គរ និងតំបន់ជុំវិញអង្គរ ក្នុងប្រទេសកម្ពុជា

### សេចក្តីផ្តើម

សន្និសិទ្ធអន្តរជាតិស្តីអំពី "ស្ថានភាពបច្ចុប្បន្ននៃបរិស្ថានក្នុងឧទ្យានអង្គរ និងតំបន់ជុំវិញឧទ្យានអង្គរក្នុងប្រទេសកម្ពុជា" នឹងប្រារព្ធធ្វើនៅថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៩ នៅមហាសាលរបស់អង្គការ UNESCO/ JASA Central Hall ក្នុងខេត្តសៀមរាប ហើយសិក្ខាសាលាស្រាវជ្រាវស្រដៀងគ្នាមួយទៀតនឹងប្រារព្ធធ្វើនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៩ នៅបន្ទប់សិក្ខាសាលានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(ITC) ក្នុងទីក្រុងភ្នំពេញ។

### វត្ថុបំណង

គោលបំណងនៃសន្និសិទ្ធ និងសិក្ខាសាលា ទីមួយ គឺដើម្បីបង្ហាញលទ្ធផលនៃបេសកកម្មស្រាវជ្រាវជាអន្តរជាតិរបស់ក្រុមERDAC ក្រោមការឧបត្ថមដោយសង្គមជប៉ុនសម្រាប់ការលើកស្ទួយវិស័យវិទ្យាសាស្ត្រ និង ដែលបានបង្កើតឡើងដើម្បីវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃការបំពុល និងការបំផ្លាញបរិស្ថានក្នុងឧទ្យានអង្គរ និង តំបន់ដែលស្ថិតនៅជុំវិញអង្គរក្នុងប្រទេសកម្ពុជាពីចំណុចផ្សេងៗគ្នានៃទស្សនៈវិទ្យាសាស្ត្រ និងជំនាញវិទ្យាសាស្ត្រ ដូចជាអំពីបរិស្ថានបរិយាកាស បរិស្ថានទឹក និងបរិស្ថានព្រៃ ហើយគោលបំណងទីពីរ គឺដើម្បីផ្លាស់ប្តូរពត៌មានដែលទាក់ទងនឹងការបំពុល និងការបំផ្លាញបរិស្ថានជាមួយអ្នកចូលរួមក្នុងសន្និសិទ្ធ និងក្នុងសិក្ខាសាលា។ ដើម្បីជម្រុញការចូលរួមឱ្យបានអធិកអធម និងស្វែងយល់បានកាន់តែប្រសើរថែមទៀតអំពីបរិស្ថានបច្ចុប្បន្នរបស់ឧទ្យានអង្គរ គ្រប់គ្នាដែលមានចំណាប់អារម្មណ៍ ឬមានជាប់ពាក់ព័ន្ធនឹងការសិក្សាអំពីបរិស្ថានត្រូវបានស្វាគមន៍ឱ្យចូលរួមក្នុងសន្និសិទ្ធ និងសិក្ខាសាលានេះ។

### ការប្រគល់អត្ថបទសង្ខេប

គណៈកម្មការរៀបចំ ស្នើសុំឱ្យអ្នកចូលរួមដែលចង់បង្ហាញប្រធានបទស្រាវជ្រាវរបស់ខ្លួននៅក្នុងសន្និសិទ្ធនៅខេត្តសៀមរាប ផ្ញើអត្ថបទស្រាវជ្រាវសង្ខេបទៅកាន់លេខាធិការសន្និសិទ្ធ។ អត្ថបទសង្ខេបគួរមានចំណុចសំខាន់ៗដូចខាងក្រោម :

-ចំណងជើងរបស់អត្ថបទស្រាវជ្រាវ

-ឈ្មោះ ទីកន្លែងធ្វើការ អាស័យដ្ឋានអ៊ីមែល លេខទូរស័ព្ទ និងអាស័យដ្ឋានអ៊ីមែលរបស់អ្នកនិពន្ធ

-មានពត៌មានលំអិតគ្រប់គ្រាន់អំពីការស្រាវជ្រាវដោយមិនឱ្យលើសពី៨០០ពាក្យ

សូមផ្ញើអត្ថបទសង្ខេបទៅកាន់ លេខាធិការសន្និសិទ្ធត្រឹម ថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩។


## សន្និសិទ្ធអន្តរជាតិ និង សិក្ខាសាលា
## ស្តីអំពីស្ថានភាពបច្ចុប្បន្ននៃបរិស្ថានក្នុងឧទ្យានអង្គរ និងតំបន់ជុំវិញអង្គរ ក្នុងប្រទេសកម្ពុជា


**សន្និសិទ្ធ : ថ្ងៃទី ១៧ មិនា ឆ្នាំ ២០០៩ នៅខេត្តសៀមរាប**

**សិក្ខាសាលា : ថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០៩ នៅភ្នំពេញ**

ទម្រង់ចុះឈ្មោះចូលរួម

ឈ្មោះ.............................................................ភេទ................

ទីកន្លែងធ្វើការ : ..................................................................

តួនាទី : ...........................................................................

អាស័យដ្ឋាន : ....................................................................

.........................................................................................

លេខទូរស័ព្ទ : ...................................ទូរសារ :............................

អ៊ីមែល: ............................................................................

ខ្ញុំនឹង (សូមគូសសញ្ញា ✓ សម្រាប់ជម្រើសរបស់អ្នក) :

( ) ចូលរួមសន្និសិទ្ធនៅសៀមរាប

( ) ចូលរួមសិក្ខាសាលានៅភ្នំពេញ

( ) ចូលរួមបង្ហាញដោយផ្ទាល់នៅក្នុងសន្និសិទ្ធ

( ) មើលប័ណ្ណប្រកាសបង្ហាញនៅក្នុងសន្និសិទ្ធ

សូមបំពេញទម្រង់ចុះឈ្មោះនេះ ហើយផ្ញើតាមរយៈអ៊ីមែល tukawaki@t.kanazawa-u.ac.jp ត្រឹមថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៩។